_ បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៣ របស់រាជរដ្ឋាភិបាលស្តីពីការតំលើងប្រាក់បៀវត្ស ២០ ភាគរយ លើបៀវត្សសុទ្ធសាធជូនមន្ត្រីរាជការ កងទ័ព និង នគរបាល

_ តាមសំណើរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១** .- តំលើងប្រាក់បៀវត្ស ២០ ភាគរយ លើបៀវត្សសុទ្ធសាធជូន ជនពិការ និង និវត្តជន។

**មាត្រា ២** .- ប្រាក់បៀវត្សដែលតំលើង ២០ ភាគរយនេះ ត្រូវអនុវត្តពីបៀវត្ស ខែ មិនា ឆ្នាំ ១៩៩៤ តទៅ។

**មាត្រា ៣** .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និង អភិបាលគ្រប់ខេត្ត ក្រុងត្រូវ ទទួលអនុវត្តអនុក្រឹត្យនេះ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

*រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ០៩ អនក្រ

**ស្តីពីការបង្កើតសេនាធិការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ សៀមរាប . បន្ទាយមានជ័យ. បាត់ដំបង.កំពង់ចាម និង ក្រុងព្រះសីហនុ**

រាជរដ្ឋាភិបាលកម្ពុជា

_ បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_ បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃព្រះរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតអគ្គសេនាធិការកងទ័ពជាតិកម្ពុជា
- ផ្អែកតាមសិក្ខាសាលា នៃការកសាងកងរាជអាវុធហត្ថឆ្នាំ ១៩៩៤ និង ដើម្បីបង្កើនការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម បង្ក្រាបរាល់អំពើល្មើសច្បាប់
- ផ្អែកតាមសំណើររបស់នាយអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ

## សំរេច

**មាត្រា ១** .- ត្រូវបានបង្កើតសេនាធិការដ្ឋាន កងរាជអាវុធហត្ថ រាជធានីភ្នំពេញ សៀមរាប បាត់ដំបង បន្ទាយមានជ័យ កំពង់ចាម និង ក្រុងព្រះសីហនុ ស្ថិតនៅក្រោមការដឹកនាំបញ្ជាផ្ទាល់របស់បញ្ជាការដ្ឋានកងអាវុធហត្ថ នៃ អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ។

**មាត្រា ២** .- រចនាសម្ព័ន្ធចាត់តាំងភារកិច្ច និង សិទ្ធិរបស់សេនាធិការកងរាជអាវុធហត្ថ រាជធានីភ្នំពេញ សៀមរាប បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម និង ក្រុងព្រះសីហនុ អាស្រ័យដោយអគ្គសេនាធិការកំណត់ ។

**មាត្រា ៣** .- ប្រគល់ជូនអគ្គសេនាធិការ កងយោធពលខេមរភូមិន្ទធ្វើការកំណត់ភារកិច្ច និង ពេលវេលាដាក់ស្តែងក្នុង ការរៀបចំសេនាធិការដ្ឋាន កងរាជអាវុធហត្ថខាងលើ ។

**មាត្រា ៤** .- អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

**មាត្រា ៥** .- អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីពេលឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

*រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ១០ អនក្រ

### ស្តីពីការបង្កើតនិធានគោលនយោបាយជីកសិកម្ម

រាជរដ្ឋាភិបាលកម្ពុជា